# អភិវឌ្ឍឲ្យកាន់តែប្រសើរ ទាំងថ្ងៃនេះ និងថ្ងៃស្អែក













# មោទកភាពចំពោះវឌ្ឍនភាពដ៏ប្រសើររបស់មហិច្ឆតាចីរភាព «បរិស្ថាន សង្គម និងអភិបាលកិច្ច»




ខេមប្រ៊ូវ ជាបុត្រសម្ព័ន្ធមួយរបស់ កាសស៊្បើរ គ្រុប ពិតជាមានមោទកភាព ដែលគោលដៅចីរភាព បរិស្ថាន សង្គម និងអភិបាលកិច្ចថ្មី «រួមគ្នាឆ្ពោះទៅកាន់ហេរ្ស៉ូ ៥ លើសពីនេះ ឬ TTZAB» មានវឌ្ឍនភាពយ៉ាងល្អប្រសើរនៅក្នុងឆ្នាំ២០២២។ ដើម្បីសម្រេចមហិច្ឆតា «គ្មានការបំភាយកាបូន» នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និងប្រតិបត្តិការទាំងមូល យើងមានការប្តេជ្ញាក្នុងការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

ក្នុងឆ្នាំ២០២២ ខេមប្រ៊ូវ សម្រេចបានលទ្ធផលការសន្សំសំចៃថាមពលអគ្គិសនី ៣៩% ជាមួយនឹងការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិចរហូតដល់ ៤៩% ធៀបនឹងឆ្នាំ២០១៩។







ជាមួយនឹងសមិទ្ធផលដ៏ប្រសើរនេះ យើងក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ លើការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព នៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ ដើម្បីឆ្ពោះទៅការសម្រេចនូវមហិច្ឆតាចីរភាព «គ្មានការខ្ជះខ្ជាយទឹក» របស់យើង។ យើងសម្រេចបានការប្រើប្រាស់ទឹកដោយស័ក្តិសិទ្ធិភាព និងសន្សំសំចៃ រហូតដល់ទៅ ៥៩% ធៀបនឹងឆ្នាំ២០១៩។

ក្នុងនាមជាក្រុមហ៊ុនផលិតស្រាបៀរ ឈានមុខគេមួយនៅកម្ពុជា យើងនឹងបន្តប្តេជ្ញារួមដំណើរជាមួយកាសស៊្បើរ គ្រុប លើគោលដៅចីរភាពបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់យើង។ ទន្ទឹមនឹងនេះ យើងក៏នឹងបន្តភាពរីកចម្រើននៃប្រតិបត្តិការអាជីវកម្មប្រកបដោយទំនួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់លើការចូលរួមអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរ ក៏ដូចជាបន្តនាំមុខគេក្នុងនាមជាប្រតិបត្តិករអាជីវកម្មដែលសកម្មក្នុងសកម្មភាពសង្គម។

*#រួមគ្នាឆ្ពោះទៅកាន់ហេរ្ស៉ូ ៥លើសពីនេះ*
*#អភិវឌ្ឍឲ្យកាន់តែប្រសើរទាំងថ្ងៃនេះ ៥ថ្ងៃស្អែក*

# ១៧៥ ឆ្នាំនៃការត្រួសត្រាយ ការចង់ដឹងចង់ឃើញ និងការអភិវឌ្ឍឥតឈប់




ប្រវត្តិសាស្រ្តរបស់កាសស្ប៊ែរ បានកើតចេញពីនវានុវត្តន៍បែបប្រពៃណីដ៏យូរលង់ និងបន្តឆន្ទៈឥតឈប់ឈរ ក្នុងការអភិវឌ្ឍសិល្បៈនៃការផលិតស្រាបៀរ។ រយៈពេល១៧៥ឆ្នាំមកនេះ យើងបានដកពិសោធន៍ និងឆ្លងកាត់ឧបសគ្គរាប់មិនអស់ ដើម្បីអភិវឌ្ឍស្រាបៀររបស់យើង រហូតទទួលបានការទទួលស្គាល់លើគុណភាព និងឱជារសដ៏ស្រស់ឈ្ងុយឆ្ងាញ់ ព្រមទាំងរក្សាបាននូវភាពឈានមុខគេនៅលើទីផ្សារ។

ដើម្បីអបអរសាទរខួបលើកទី ១៧៥ កាសស្ប៊ែរ បានផលិតនូវប្រភេទស្រាបៀរពិសេសមួយចំនួន ដែលកើតចេញពីគំនិតច្នៃប្រឌិត របស់មន្ទីរពិសោធន៍ស្រាវជ្រាវ កាសស្ប៊ែរ (Carlsberg Research Laboratory) ។

ដើម្បីអបអរឆ្នាំចាស់ ស្វាគមន៍ឆ្នាំថ្មី ២០២៣ កាសស្ប៊ែរ ដែលទំនងជាស្រាបៀរដ៏ល្អបំផុតលំដាប់ពិភពលោក បានរឹតចំណងទំនាក់ទំនងជាមួយសហសេវិក អតិថិជន ដៃគូអាជីវកម្ម និងដៃគូពាក់ព័ន្ធ ជាមួយស្រាបៀរ កាសស្ប៊ែរ Brut ដ៏ពិសេស ទាំងរូបរាង ការវេចខ្ចប់ និងគ្រឿងផ្សំ ដែលចម្រាញ់ពីគ្រឿងផ្សំដ៏ល្អពិសេស ដូចជា មេដំបែ Montrahet ក្រូច yuzu ក្រូច Grapefruit zest និងទឹកផ្កាកុលាប ដែលមានសាធាតុកាបូណាតខ្ពស់ និងរសជាតិឈ្ងុយឆ្ងាញ់។

ឆ្នាំនេះ ស្រាបៀរ កាសស្ប៊ែរ នឹងនៅជាមួយអ្នក ដើម្បីអបអរភាពជោគជ័យជាមួយគ្នា និងបង្កើនបរិយាកាសជួបជុំជាមួយក្រុមគ្រួសារ និងមិត្តភក្តិកាន់តែរីករាយ។

តោះ! ចូលរួមអបអរសាទរដល់កាសស្ប៊ែរ និងជូនពរឱ្យអាជីវកម្មរបស់យើងកាន់តែរីកចម្រើន។

# តើអ្នកជាអ្នកលក់ ឬជាអ្នកជួយលក់?






សហសេវិកទាំងអស់នៅការិយាល័យកណ្ដាលរាជធានីភ្នំពេញ បានចុះទស្សនកិច្ចទីផ្សាររយៈពេលពេញមួយថ្ងៃ នៅតំបន់លក់ប៉ែកកណ្ដាល ដើម្បីពញ្ញាក់ការចូលរួមឱ្យកាន់តែខ្លាំងក្លាពីបុគ្គលិកគ្រប់ផ្នែក ព្រោះថាពួកយើងទាំងអស់នៅខេមប្រ៊ូវ មានតួនាទី និងទំនួលខុសត្រូវរួមគ្នាមួយ នោះគឺចូលរួមរក្សាភាពជាក្រុមហ៊ុននាំមុខគេមួយនៅកម្ពុជា តាមរយៈតួនាទីជាអ្នកលក់ប្រយុទ្ធនៅលើទីផ្សារ និងជាអ្នកជួយជំរុញការលក់នៅពីក្រោយការប្រយុទ្ធ។








ទស្សនកិច្ចទីផ្សារនេះ ក៏ផ្ដល់ឱ្យសហសេវិកនូវបទពិសោធន៍លក់ជាក់ស្ដែង អង្កេតពីសក្ដានុពលផលិតផលនៅទីផ្សារ និងស្វែងយល់ពីភាពប្រកួតប្រជែងរបស់ផលិតផលនៅក្នុងទីផ្សារ ក៏ដូចជាបញ្ហាប្រឈមនានា ដែលសហសេវិកផ្នែកលក់ និងទីផ្សារផលិតផលរបស់យើងកំពុងជួបប្រទះ។ ទស្សនកិច្ចទីផ្សារដោយផ្ទាល់នេះ ធ្វើឡើងកាលពីថ្ងៃទី១៦ និង១៧ ខែមករា ឆ្នាំ២០២៣ ដោយចែកជា ៨៣ ក្រុមផ្សេងគ្នា។
បន្ទាប់ពីទស្សនកិច្ចប្រកបដោយផ្លែផ្កានេះ សហសេវិកក៏បានរាយការណ៍ពីកង្វល់ ផ្ដល់មតិយោបល់ សំណូមពរ និងដំណោះស្រាយល្អៗ ដែលទិន្នន័យទាំងនេះនឹងក្លាយជាធាតុចូលយ៉ាងសំខាន់ នៅក្នុងការជំរុញកំណើនលក់ ឲ្យកាន់តែប្រសើរនៅក្នុងទីផ្សារដ៏ប្រកួតប្រជែងមួយនេះ។

១៥-កុម្ភៈ-២០២៣ /លេខ៖ CAMJAN2023#3

# ជម្នះឧបសគ្គ យើងនឹងបង្កើតភាពជោគជ័យរួមគ្នា




ពិធីជប់លៀងបុគ្គលិក ខេមប្រ៊ូវ សម្រាប់ឆ្នាំ២០២២ បានរៀបចំឡើង ក្នុងគោលបំណងថ្លែងអំណរគុណដល់បុគ្គលិកគ្រប់រូបរបស់ខេមប្រ៊ូវ ដែលចូលរួមចំណែកយ៉ាងសស្រាក់សស្រាំ ក្នុងការដឹកនាំ និងជំរុញប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។






អគ្គនាយកគ្រប់គ្រងខេមប្រ៊ូវ Vladimir បានឡើងថ្លែងអំណរគុណ និងគោរពកោតសរសើរខ្ពស់ ដល់សហសេវិកទាំងអស់ ដែលតែងតែរឹងមាំ និងខ្នះខ្នែងបំពេញការងារនាពេលកន្លងមក។ អគ្គនាយកគ្រប់គ្រងរបស់យើងក៏មានប្រសាសន៍ថា យើងនឹងបន្តរួបរួមគ្នាជាធ្លុងមួយ ដើម្បីជំរុញអាជីវកម្មរបស់យើងកាន់តែរីកចម្រើន ក្លាយជាទម្លាប់ ហើយយើងនឹងធ្វើឱ្យឆ្នាំ២០២៣ គឺជាឆ្នាំដ៏អស្ចារ្យ ជាឆ្នាំដែលអាជីវកម្មយើងរីកចម្រើនជាមួយឧត្តមភាព។




ដ្បិតថាឆ្នាំ២០២៣ ជាឆ្នាំដ៏គួរឱ្យកង្វល់សម្រាប់យើង ខណៈពេលដែលបញ្ហាប្រឈមជាច្រើនបាន និងកំពុងកើតឡើង ដូចជាកំណើនអត្រាអតិផរណា ទំនិញឡើងថ្លៃ និងវិវាទភូមិសាស្ត្រនយោបាយ ប៉ុន្តែយើងជឿជាក់លើភាពខ្លាំង និងភាពធន់របស់សហសេវិក ខេមប្រ៊ូវ - ពួកគេខ្លាំងជាងអ្វីដែលពួកគេគិត។ យើងបានជម្នះឧបសគ្គជាច្រើនរួចមកហើយ ដែលនេះជាតឹកតាងបញ្ជាក់យ៉ាងច្បាស់ ពីភាពខ្លាំងរបស់សហសេវិកយើង។






យើងទាំងអស់គ្នា ពិតជាត្រូវទទួលបានការទះដៃអបអរសាទរសម្រាប់ការលះបង់ដោយឥតលក្ខខណ្ឌនេះ។យើងសង្ឃឹមថាពួកយើងនឹងអាចរៀបចំពិធីជប់លៀងប្រចាំឆ្នាំជាមួយគ្នាយ៉ាងរីករាយបែបនេះ ជារៀងរាល់ឆ្នាំ ប៉ុន្តែអាចបាន ឬមិនបាន គឺអាស្រ័យលើយើងទាំងអស់គ្នា។

**តោះ! ផ្តើមឆ្នាំថ្មីដ៏ខ្លាំងក្លា ហើយយើងក៏នឹងបញ្ចប់ទៅវិញដោយភាពកាន់តែខ្លាំងក្លាជាមួយគ្នា!**

# អបអរជ័យលាភីនៃការអនុវត្ត ស៥ ល្អបំផុត ប្រចាំឆ្នាំនៅរោងចក្រផលិតស្រាបៀររបស់យើង - តើផ្នែកណានឹងទទួលបានជ័យលាភីបន្ទាប់?




1st
place 5S competition




2nd
place 5S competition



3rd
place 5S competition

សូមចូលរួមអបអរសាទរដល់ក្រុមការងារ ដែលបានឈ្នះពានរង្វាន់ប្រចាំឆ្នាំ ពីការប្រកួតប្រជែងក្នុងការអនុវត្ត ស៥ (សម្រិតសម្រាំង សណ្ដាប់ធ្នាប់ សម្អាត ស្តង់ដារ និងស្ថិរភាព) ប្រចាំរោងចក្រផលិតស្រាបៀររបស់យើង។ កម្មវិធីប្រកួតប្រជែងនេះ រៀបចំឡើង ដើម្បីលើកកម្ពស់ និងជំរុញការចូលរួមពីសហសេវិក ក្នុងការរក្សាបាននូវកន្លែងការងារល្អប្រកបដោយឥរិយាបថ ស៥ និងផ្តល់ការកោតសរសើរដល់ក្រុមការងារ ដែលបានរៀបចំកន្លែងធ្វើការមានសណ្ដាប់ធ្នាប់ របៀបរៀបរយបំផុត។

**Best Kaizen**




**Coach**

**Soun Sreynuch**



**Kong Kea**

**Best Kaizen Executor**



**Sambath Dyna**

នៅឆ្នាំ២០២២ យើងមាន៦ផ្នែកដែលបានចូលរួមការប្រកួត និងត្រូវបានវាយតម្លៃកាលពីថ្ងៃទី២៧-២៨ ខែធ្នូ ឆ្នាំ២០២២ ដោយគណៈកម្មការដែលជាតំណាងមកពីផ្នែកសុខភាព ៥សុវត្ថិភាព ធនធានមនុស្ស និងផ្នែកឧត្តមភាព។ តាមរយៈការវិនិច្ឆ័យយ៉ាងម៉ត់ចត់ យើងបានរកឃើញផ្នែកដែលមានការអនុវត្តស្តង់ដារ ស៥ ល្អបំផុតប្រចាំឆ្នាំ ដូចជា៖

**រង្វាន់លេខ១** បានទៅផ្នែកតំហែទាំ
**រង្វាន់លេខ ២** បានទៅផ្នែក B&P loading
**និងរង្វាន់លេខ ៣** បានទៅផ្នែក ABC CIP station

សូមអរគុណសហសេវិកទាំងអស់ ចំពោះការចូលរួមយ៉ាងសកម្ម ហើយយើងនឹងបន្តអនុវត្តស្តង់ដារ ស៥ ឱ្យបានខ្ជាប់ខ្ជួន ដើម្បីការងាររបស់យើងកាន់តែមានប្រសិទ្ធភាព ផលិតភាព និងមានសុវត្ថិភាព ស្របតាមគោលដៅចីរភាព«គ្មានវប្បធម៌គ្រោះថ្នាក់»។

## Kaizen Champion



Kheng Sambatmaryde



Chan Na

## Kaizen Special Prize



Tim Pisey



Men Rotana



Keut Dorn



Um Veasna

# ឆ្នាំថ្មី ការប្តេជ្ញាថ្មី! ភាពជោគជ័យ និង សមិទ្ធផលថ្មី នឹងនៅតែបន្ត




ឆ្នាំថ្មី ខែថ្មី ថ្ងៃថ្មី ការចាប់ផ្តើមថ្មី បំណងប្រាថ្នាថ្មី ការប្តេជ្ញាថ្មី និងជាប្រភពនៃការបំផុសគំនិតថ្មីៗ រឿងរ៉ាវល្អៗ នឹងនៅតែបន្ត។ សហសេវិករបស់យើងចំនួន ៤រូប មកពីផ្នែកផ្សេងគ្នា បានចែករំលែក «បទពិសោធន៍ឆ្នាំចាស់ កំណត់គោលដៅឆ្នាំថ្មី» របស់ខ្លួន។ តើពួកគាត់ទទួលបានបទពិសោធន៍អ្វីខ្លះក្នុងឆ្នាំ២០២២ ក៏ដូចជាមានការប្តេជ្ញាអ្វីសម្រាប់ឆ្នាំ ២០២៣?

គឹម លីណា ជាជំនួយការប្រធានគ្រប់គ្រងផ្នែកស្រាវជ្រាវទីផ្សារ ហើយក៏ជាសហសេវិកមួយរូបដែលទទួលបានពានរង្វាន់ពីកម្មវិធីបុគ្គលិកប្រចាំខែឧសភា ឆ្នាំ២០២២ ផងដែរ។ លីណា បានរៀបរាប់ពីការរៀនសូត្រ និងទទួលបទពិសោធន៍ជាច្រើនក្នុងឆ្នាំ២០២២ ជាពិសេសគឺការកសាងក្រុមការងារល្អ ដែលអាចសម្រេចនូវមហិច្ឆតាជាច្រើនរួមគ្នា។ គោលដៅឆ្នាំថ្មីឆ្នាំ២០២៣ លីណា នឹងបន្តអភិវឌ្ឍសមត្ថភាព រៀនអ្វីថ្មីៗ ធ្វើដំណើរទៅកន្លែងផ្សេងដើម្បីទទួលយកបទពិសោធន៍ថ្មីៗ និងរឿងរ៉ាវល្អ ព្រមទាំងលើកទឹកចិត្តក្រុមការងារ ឱ្យបន្តបង្កើនសមត្ថភាពខ្លួនជាបន្តបន្ទាប់។

ចំណែក ស៊ិន សាយណ្ណ ប្រធានផ្នែកឃ្លាំង បានរំឭកពីដំណើរកម្សាន្តដ៏រីករាយជាមួយក្រុមគ្រួសារទៅខេត្តព្រះសីហនុក្នុងឆ្នាំ២០២២។ សាយណ្ណ បានតាំងចិត្តបន្តអភិវឌ្ឍជំនាញបច្ចេកទេស ក្នុងតួនាទីរបស់ខ្លួនបច្ចុប្បន្ន និងជំនាញទន់ ជាពិសេសកសាងក្រុមការងារដែលរឹងមាំ និងបន្តការសហការជាមួយផ្នែកផ្សេងទៀត ដើម្បីភាពរីកចម្រើនទាំងអស់គ្នា។

សម្រាប់ ជូ សុភក្រ ដែលជាអ្នកប្រតិបត្តិផ្នែកទីផ្សារពាណិជ្ជកម្មវិញ បានប្តេជ្ញាប្រឹងប្រែងធ្វើឱ្យការងាររបស់ខ្លួនកាន់តែលេចធ្លោជាមួយនឹងការកសាងក្រុមការងារដែលយល់ចិត្តគ្នា ប្រកបដោយឆន្ទៈក្រុមតែមួយ។

ចំណេះដឹងថ្មី និងបទពិសោធន៍ល្អៗជាច្រើន គឺជាអ្វីដែល ទូច វ៉ារ៉ុន អ្នកសម្របសម្រួលផ្នែកជំរុញការលក់ ទទួលបាននៅក្នុងឆ្នាំចាស់ ហើយការធ្វើដំណើរទៅក្រៅប្រទេស និងការអភិវឌ្ឍជំនាញរឹង និងជំនាញទន់ គឺជាគោលដៅអាទិភាពសម្រាប់ឆ្នាំថ្មីរបស់គាត់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សហសេវិកទាំងអស់ ដែលគ្រប់គ្នាសុទ្ធតែមានចំណែកនៅក្នុងភាពរីកចម្រើនរបស់ក្រុមហ៊ុន។ យើងទន្ទឹងរង់ចាំនូវសមិទ្ធផល និងភាពជោគជ័យថ្មីៗជាច្រើនទៀត នៅក្នុងឆ្នាំថ្មី ឆ្នាំ២០២៣ ពីសហសេវិកដែលពោរពេញដោយថាមពល និងសក្តានុពល។

# បន្តបង្កើនអ្នកដឹកនាំដែលមានគុណវុឌ្ឍិ ដើម្បីឆ្ពោះទៅរកភាពរីកចម្រើនកាន់តែប្រសើរ







នៅ កាសស្បៀរ គ្រុប រួមទាំងនៅខេមប្រ៊ូវផងដែរនោះ បុគ្គលិកជាទ្រព្យដ៏មានតម្លៃបំផុតមួយរបស់ក្រុមហ៊ុន ហើយយើងបាន និងកំពុងប្រឹងប្រែងអភិវឌ្ឍសមត្ថភាពរបស់សហសេវិកឱ្យកាន់តែខ្លាំង និងក្លាយជាអ្នកដឹកនាំភាពជាគំរូប្រកបដោយគុណវុឌ្ឍិក្នុងការអនុវត្តការងារ និងបង្កើតវប្បធម៌ A ទាំងបី (ការស្របគ្នាតែមួយ ការទទួលខុសត្រូវ និងការអនុវត្ត) ដូចអ្វីដែលថ្នាក់ដឹកនាំ កាសស្បៀរ រំពឹងពីសហសេវិកគ្រប់រូប។



ដើម្បីពង្រីកវិសាលភាពនៃភាពជាអ្នកដឹកនាំ ដែលជាកម្លាំងចលករដ៏សំខាន់មួយ នៅក្នុងការរួមចំណែកដល់ភាពរីកចម្រើនឥតឈប់ឈររបស់ក្រុមហ៊ុន យើងបានបង្កើតវគ្គបណ្តុះបណ្តាលស្តីពី «ការអភិវឌ្ឍភាពជាអ្នកដឹកនាំ»  ដល់អ្នកដឹកនាំជាង ៤០ រូប មកពីផ្នែកផ្សេងគ្នា។ វត្ថុបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺបំពាក់បំប៉នជំនាញ ផ្តល់បទពិសោធន៍ និងចំណេះដឹងបន្ថែមដល់អ្នកដឹកនាំ ក៏ដូចជាឱ្យការអនុវត្តការងាររបស់ពួកគាត់កាន់តែមានស័ក្តិសិទ្ធិភាព ព្រមទាំងបន្ថែមគុណតម្លៃដល់ប្រតិបត្តិការអាជីវកម្មរបស់យើង។ យើងនៅតែបន្តបង្កើនអ្នកដឹកនាំប្រកបដោយគុណវុឌ្ឍិ និងពោរពេញដោយឆន្ទៈ ក្នុងការធ្វើការរួមគ្នា ដើម្បីរក្សាបាននូវភាពជាក្រុមហ៊ុនឈានមុខគេមួយនៅកម្ពុជា ដែលមានប្រតិបត្តិការអាជីវកម្មប្រកបដោយទំនួលខុសត្រូវ មានការទទួលស្គាល់សម្រាប់សហសេវិក ពាណិជ្ជសញ្ញា ការអនុវត្ត និងចូលរួមចំណែកអភិវឌ្ឍសង្គម។










# ខេមប្រ៊ូវ បន្តអភិវឌ្ឍធនធានមនុស្ស ដែលជាទ្រព្យដ៏មានតម្លៃបំផុតមួយរបស់ខ្លួន



ធនធានមនុស្សដែលពោរពេញដោយចំណេះជំនាញ ការអនុវត្តការងារល្អ និងមានប្រាស្រ័យទាក់ទងល្អជាមួយគ្នា គឺជាធនធានដែលដ៏មានតម្លៃបំផុត ព្រោះថាចំណេះជំនាញរបស់សហសេវិក នឹងធានានិរន្តរភាពនៃការរីកចម្រើន ភាពប្រកួតប្រជែង និងបង្កើតឱ្យមានភាពសុខដុមរមនានៅកន្លែងធ្វើការ។ ដើម្បីសម្រេចតាមយុទ្ធសាស្រ្ត SAIL’27 របស់ កាសស្បឺរ គ្រុប ការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស គឺជាយុទ្ធសាស្រ្តដ៏ត្រឹមត្រូវមួយដែលយើងត្រូវវិនិយោគ ដើម្បីបង្កើតទីកន្លែងការងារ ដែលមានការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងឆ្នាំ២០២២ ខេមប្រ៊ូវ បានរៀបចំវគ្គបណ្តុះបណ្តាលអនឡាញ តាមរយៈ LinkedIn Learning ដល់សហសេវិកខេមប្រ៊ូវ។

ការបណ្តុះបណ្តាលនេះក្រុមទី១ បានបែងចែកជា ៤ វគ្គ សម្រាប់រយៈពេល ៤ ត្រីមាស ដែលផ្តោតលើ ទំនាក់ទំនង ភាពជាអ្នកដឹកនាំ ការអភិវឌ្ឍជំនាញគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន។ សហសេវិកចំនួន ១៧៨ នាក់ ត្រូវបានជ្រើសរើស ឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ដែលមានម៉ោងសិក្សាសរុបគឺ៤២ម៉ោង។ យើងនឹងបន្តបណ្តុះបណ្តាលសហសេវិកទាំងអស់នៅក្នុងឆ្នាំបន្តបន្ទាប់។ ដើម្បីឱ្យវគ្គបណ្តុះបណ្តាលកាន់តែមានភាពរស់រវើក និងសកម្មថែមទៀតនោះ នៅរៀងរាល់ត្រីមាសនីមួយៗ យើង ជ្រើសរើសសិក្ខាកាមសកម្មជាងគេចំនួន ៥នាក់ ដើម្បីផ្តល់លើកទឹកចិត្តបន្ថែម។ គិតត្រឹមពេលនេះ យើងនឹងមានសិក្ខាកាមសកម្មសរុបចំនួន ២០ រូប។ ការអភិវឌ្ឍសមត្ថភាពឥតឈប់ឈរ គឺជាគោលដៅ និងស្របតាមចក្ខុវិស័យរបស់ក្រុមហ៊ុន។ យើងនៅតែបន្តមានទំនុកចិត្ត លើសមត្ថភាពរបស់បុគ្គលិក ដើម្បីរួមគ្នាឆ្ពោះទៅរកភាពរីកចម្រើនជាចីរភាព និងសង្គតិភាព។



# ស្រាបៀរ អង្គរ មកជាមួយភាព “ចែងចាំងដូចមាស រូបរាងថ្មី រសជាតិថ្មីស្រស់”




ស្របតាមគោលបំណង និងយុទ្ធសាស្ត្ររបស់ស្រាបៀរ អង្គរ ដែលតែងតែផ្តល់បទពិសោធន៍ថ្មីៗ ជូនដល់អតិថិជន ទាំងចំណង់ចំណូលចិត្ត និងភាពច្នៃប្រឌិតខ្ពស់ នាពេលថ្មីៗនេះ ស្រាបៀរអង្គរ បានមកជាមួយនឹងរូបរាងដែលមានក្បាច់រចនាថ្មី អង្រួនបេះដូងអតិថិជនជាមួយមោទកភាពជាតិ តាមរយៈរចនាបទខ្មែរ ក្រោមសារ «ចែងចាំងដូចមាស រូបរាងថ្មី រសជាតិថ្មីស្រស់»។






ចែងចាំងដូចមាស រូបរាងថ្មី រសជាតិថ្មីស្រស់ ជាផ្នែកមួយនៃយុទ្ធសាស្ត្រដ៏អង់អាច និងច្បាស់លាស់របស់ស្រាបៀរអង្គរ ដើម្បីពង្រឹងកិត្តិស័ព្ទរបស់ពាណិជ្ជសញ្ញាមួយនេះ ឱ្យកាន់តែរស់រវើក និងល្បីរន្ទឺ ក៏ដូចជា ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនកម្ពុជារាប់លាននាក់ ដែលតែងតែនិយមគាំទ្រយ៉ាងស្មោះស្ម័គ្រចំពោះស្រាបៀរអង្គរ ជាពិសេសអតិថិជនជំនាន់ថ្មី ដែលតែងតែឱ្យតម្លៃលើគុណភាព និងចង់ដឹងចង់យល់កាន់តែច្បាស់អំពីបទពិសោធន៍ពីស្រាបៀរដែលខ្លួនកំពុងគាំទ្រ។ ចែងចាំងដូចមាស រូបរាងថ្មី រសជាតិថ្មីស្រស់ ជាសក្ខីភាពមួយបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់យើង ក្នុងការផលិតស្រាបៀរអង្គរ ឱ្យកាន់តែល្អប្រសើរទាំងគុណភាព និងរសជាតិ ក៏ដូចជារក្សាបំណងមិនដែលផ្លាស់ប្តូរ ក្នុងការច្នៃប្រឌិត និងផ្តល់ជូនអតិថិជននូវបទពិសោធន៍កាន់តែអស្ចារ្យ។ យើងជឿជាក់ថា យុទ្ធនាការថ្មីនឹងចូលរួមចំណែកឱ្យពាណិជ្ជសញ្ញាអង្គរកាន់តែរីកចម្រើន និងទទួលបានការគាំទ្រកាន់តែច្រើន។




*#ពិសាគ្រឿងស្រវឹង សូមកុំបើកបរ!*
*#រួមគ្នាឆ្ពោះទៅកាន់គ្មានការពិសាគ្រឿងស្រវឹងដោយគ្មានទំនួលខុសត្រូវ*

# គ្មានឡើយ ការស៊ីសំណូក និងពុករលួយ



នៅខេមប្រ៊ូវ យើងមិនត្រឹមតែជំរុញទឹកចិត្តអតិថិជន អ្នកផ្គត់ផ្គង់ ដៃគូពាក់ព័ន្ធរបស់យើង និងសហគមន៍ដែលយើងមានប្រតិបត្តិការ តាមរយៈការផ្តល់នូវរសជាតិស្រាបៀរដ៏ល្អឥតខ្ចោះ និងគុណភាពខ្ពស់បំផុតប៉ុណ្ណោះទេ យើងក៏ទាក់ទាញទឹកចិត្តពួកគាត់ តាមរយៈការប្តេជ្ញាខ្ពស់ក្នុងការដឹកនាំប្រតិបត្តិការអាជីវកម្ម ប្រកបដោយស្តង់ដារខ្ពស់បំផុត - ដោយប្រកាន់ខ្ជាប់នូវការអនុវត្តខ្លួនយើងប្រកបដោយក្រមសីលធម៌ និងធ្វើរឿងដែលត្រឹមត្រូវ។
មិនមែនជារឿងងាយស្រួលប៉ុន្មានទេ ដែលកាសស្បៀរ ត្រូវចូលស្ទឹងតាមបត់ នៅតាមទីផ្សារពោរពេញដោយការប្រកួតប្រជែងនៅជុំវិញពិភពលោក ដើម្បីបង្ហាញនូវស្រាបៀរដែលទំនងជាស្រាបៀរដ៏ល្អបំផុតលំដាប់ពិភពលោក។ ការងារមួយ ដែលយើងត្រូវតែធ្វើជាប្រចាំ នោះគឺការចូលរួមប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងអំពើស៊ីសំណូក។
ខេមប្រ៊ូវ បានខិតខំយ៉ាងពេញទំហឹងក្នុងការរក្សាភាពជាគំរូ និងជាពន្លឺដ៏សំខាន់មួយ ដែលបង្ហាញអំពីក្តីសង្ឃឹមក្នុងការឆ្ពោះទៅរកតម្លាភាព។ សម្រាប់ពួកយើង រាល់ទង្វើស៊ីសំណូក សូកប៉ាន់ គឺជាសកម្មភាពមួយដែលបង្ហាញពីភាពមិនស្មោះត្រង់ មិនមានកិត្តិយស សីលធម៌ និងមិនអាចអត់ឱន។
ដោយពិចារណាយ៉ាងយកចិត្តទុកដាក់លើកង្វល់ទាំងអស់នេះ នៅក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្ស ក្រុមហ៊ុនបានបង្កើតគោលការណ៍ណែនាំនានា ដើម្បីទប់ស្កាត់អំពើពុករលួយនៅក្នុងក្រុមហ៊ុន ក៏ដូចជាការប្រាស្រ័យទាក់ទងជាមួយនឹងដៃគូពាក់ព័ន្ធផ្សេងទៀត ព្រមទាំងបានបំពាក់បំប៉ន់ តាមរយៈវគ្គបណ្តុះបណ្តាល ជាពិសេសសម្រាប់សហសេវិក គ្រប់ផ្នែកទៅតាមតួនាទីរបស់ពួកគាត់។



សហសេវិកប្រមាណជាង ៨០ រូប បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរម្លឹក អំពីការទប់ស្កាត់អំពើពុករលួយ និងអំពើស៊ីសំណូក ដែលធ្វើឡើងដោយនាយកដ្ឋានច្បាប់ របស់ខេមប្រ៊ូវ។
នេះដើម្បីធានាដំណើរការការងារឲ្យបានរលូន បើទោះបីការងារនោះជាការងារផ្ទៃក្នុង ឬជាការងារជាមួយដៃគូពាក់ព័ន្ធខាងក្រៅក៏ដោយ។ គិតត្រឹមចុងឆ្នាំ២០២២ សហសេវិកចំនួន ៩៨% បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដោយជោគជ័យ។
ជាមួយនឹងការកើនឡើង នៃការទាមទារជាចាំបាច់ឱ្យមានការអនុវត្តការងារប្រកបដោយក្រមសីលធម៌ នៅជុំវិញពិភពលោក ការមិនបានរក្សាខ្លួនយើងជាគំរូដ៏ល្អ លើការអនុវត្តតាមបទប្បញ្ញត្តិច្បាប់ អាចនាំឲ្យមានមហន្តរាយដល់អាជ្ញាបណ្ណអាជីវកម្ម កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ក៏ដូចជាឱកាសរីកចម្រើននានា។
នៅខេមប្រ៊ូវ យើងធានាថា គ្រប់ផលិតផលនីមួយៗរបស់យើង មិនមែនត្រឹមតែផលិតឡើងពីគ្រឿងផ្សំដ៏ល្អបំផុត និងផលិតដោយស្តង់ដារខ្ពស់ប៉ុណ្ណោះទេ តែក៏ផលិតឡើងជាមួយនឹងប្រតិបត្តិការអាជីវកម្មដែលពោរពេញដោយវិជ្ជាជីវៈ មានក្រមសីលធម៌ខ្ពស់បំផុតរបស់យើងផងដែរ។
យើងរួមគ្នាអភិវឌ្ឍឲ្យកាន់តែប្រសើរទាំងថ្ងៃនេះនិងថ្ងៃស្អែក ដោយខិតខំប្រឹងប្រែងធ្វើយ៉ាងណា ឱ្យអំពើពុករលួយក៏ដូចជាអំពើស៊ីសំណូក ជារឿងមួយដែលមានតែនៅក្នុងអតីតកាលប៉ុណ្ណោះ។



CAMBREW LTD

Part of the Carlsberg Group

# បង្កើតវប្បធម៌រីកចម្រើនជាមួយគ្នា!

No. 1881, Russian Boulevard, Phum Ta gnoun, Sangkat Kakab, Khan Posenchey, Phnom Penh, Kingdom of Cambodia

+855 (0) 23 987 905

info.kh@carlsberg.asia

Cambrew Ltd

Cambrewltd

Cambrew Ltd

www.carlsberggroup.com/
www.cambrew.com.kh/